00366530

D164/4/6

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ការដាក់ឯកសារ**

**សំណុំរឿងលេខ៖** ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អបជ២២)

**ភាគីអ្នកតម្កល់៖** ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន

**ដាក់តម្កល់ជូន៖** អង្គបុរេជំនុំជម្រះ

**ភាសាដើម៖** ភាសាបារាំង

**កាលបរិច្ឆេទដាក់ឯកសារ៖**

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ស្នើឡើងដោយភាគីអ្នកតម្កល់៖ សាធារណៈ

ចំណាត់ថ្នាក់សម្រេចដោយសហចៅក្រមស៊ើបអង្កេត៖

លក្ខន្តិកៈនៃចំណាត់ថ្នាក់៖

ការពិនិត្យឡើងវិញនូវចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿងនិងបណ្ណសារ៖

ហត្ថលេខា៖

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 08 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សំណើសុំឲ្យពិនិត្យមើលឡើងវិញនូវ "សេចក្តីសម្រេចទាក់ទងនឹងសំណើសុំឲ្យមានសវនាការដើម្បីពិនិត្យបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អ.ប.ជ - ២៤ និង ២៥**

---

**បញ្ជូនដោយ៖**

**សហមេធាវីរបស់លោក ខៀវ សំផន**

មេធាវី ស ស្វាន

មេធាវី Jacques VERGÈS

**អ្នកជំនួយការ**

**លោកស្រី សេង សុជាតា**

**កញ្ញា Charlotte MOREAU**

**លោក Uldis KRASTINS**

**បញ្ជូនទៅ៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន៉យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និង ដើមបណ្តឹងរដ្ឋប្បវេណី**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## ជូនចំពោះអង្គបុរេជំនុំជម្រះ

## សេចក្តីផ្តើម

1. តាមរយៈសេចក្តីសម្រេចចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានប្រកាសថា ខ្លួនបានបដិសេធសំណើរបស់សហមេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធិ លោក នួន ជា លោក ខៀវ សំផន ក្នុងការពិនិត្យនៅក្នុងសវនាការ នូវអំណះអំណាងរបស់ភាគីនានាស្តីពីបណ្តឹងឧទ្ធរណ៍របស់ពួកគេប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងសំណុំឯកសាររួម[1]។
2. សេចក្តីសម្រេចនេះមិនមែនត្រឹមតែជាសេចក្តីសម្រេចដោយឡែកប៉ុណ្ណោះទេ។ជាការពិត សេចក្តីសម្រេចនេះកំណត់នូវវិធានថ្មីមួយទាក់ទងនឹងសវនាការបណ្តឹងឧទ្ធរណ៍ ដែល"ជាលក្ខណៈទូទៅ [អង្គបុរេជំនុំជម្រះ]ត្រូវសម្រេចសេចក្តី ដោយឈរលើមូលដ្ឋានតែមួយគត់នៃសេចក្តីសង្ខេបជាលាយលក្ខណ៍អក្សររបស់ភាគីនានា លើប្រភេទពិសេសនៃបណ្តឹងឧទ្ធរណ៍នេះដែលជាបណ្តឹងធ្វើឡើងប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ"[2]។ បើតាមអង្គបុរេជំនុំជម្រះ នេះគឺជា "លក្ខណៈសម្គាល់នៃការស៊ើបសួរ ដូចដែលមានចែងនៅក្នុងវិធាន ៥៦ នៃវិធានផ្ទៃក្នុង [ដែល]បង្គាប់ឲ្យមានវិធីបែបនេះ"[3]។
3. ដូច្នេះ តាមការពិចារណានេះ វាគឺជាការគ្រប់គ្រាន់ដែលបណ្តឹងឧទ្ធរណ៍មួយស្ថិតនៅក្នុងប្រភេទនេះ ដើម្បីលែងឲ្យត្រូវចោទសួរអំពីកាលានុវត្តភាពនៃសវនាការមួយ។ ហើយសវនាការនេះត្រូវបានសន្និដ្ឋានថាគ្មានប្រយោជន៍។ គឺដោយឈរលើមូលដ្ឋាននេះហើយ ដែលអង្គបុរេជំនុំជម្រះបាន

---

[1] បណ្តឹងឧទ្ធរណ៍តែមួយគត់របស់ក្រុមការពារក្តី ប្រឆាំងនឹងដីកាចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ របស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងសំណើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងសំណុំឯកសាររួម ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ *ឯកសារតុលាការ D164/4/1* (បន្ទាប់ពីនេះ "បណ្តឹងឧទ្ធរណាណ៍")

[2] សេចក្តីសម្រេចទាក់ទងនឹងសំណើសុំឲ្យមានសវនាការ ដើម្បីពិនិត្យបណ្តឹងឧទ្ធណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អ.ប.ជ ចុះថ្ងៃទី២៤ និង ២៥ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ *ឯកសារតុលាការ D164/4/3* កថាខណ្ឌទី ៥

[3] សេចក្តីសម្រេចទាក់ទងនឹងសំណើសុំឲ្យមានសវនាការ ដើម្បីពិនិត្យបណ្តឹងឧទ្ធណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អ.ប.ជ ចុះថ្ងៃទី២៤ និង ២៥ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ *ឯកសារតុលាការ D164/4/3* កថាខណ្ឌទី ៥

[សំណើសុំឲ្យពិនិត្យមើលឡើងវិញនូវ "សេចក្តីសម្រេចទាក់ទងនឹងសំណើសុំឲ្យមានសវនាការដើម្បីពិនិត្យបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អ.ប.ជ ២៤ និង ២៥]

សម្អាងលើ ដើម្បីបដិសេធសំណើសុំឱ្យមានសវនាការរបស់សហមេធាវីការពារក្តីនៅក្នុងករណីនេះ ហើយដោយហេតុដូច្នេះ អង្គបុរេជំនុំជម្រះបានបង្គាប់ឱ្យសហមេធាវីដាក់ចម្លើយតបចំពោះចម្លើយរបស់សហព្រះរាជអាជ្ញា ទៅតាមរយៈពេលដែលមានចែងនៅក្នុងសេចក្តីណែនាំអនុវត្ត។

4. សំណើសុំឱ្យពិនិត្យមើលឡើងវិញនេះពិតជាទាក់ទងនឹងទិដ្ឋភាពទាំងពីរនៃសេចក្តីសម្រេច៖ម្យ៉ាងគឺជាការប្រកាសនូវវិធានមួយដែលមានលក្ខណៈទូទៅ ស្តីពីការបើកសវនាការបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ហើយម្យ៉ាងទៀត គឺជាសេចក្តីសម្រេចពិសេសរបស់អង្គបុរេជំនុំជម្រះស្តីពីបណ្តឹងឧទ្ធរណ៍ នៅក្នុងក្របខណ្ឌនៃសវនាការទាក់ទងនឹងសំណុំឯកសាររួម។ នេះគឺជាសេចក្តីសម្រេចពីរដែលគួរតែពិនិត្យដាច់ដោយឡែកពីគ្នានិងជាបន្តបន្ទាប់។

## I. សំណើសុំឱ្យពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេចដែលកំណត់សិទ្ធិសវនាការបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ

5. វិធានទូទៅដែលកំណត់ដោយអង្គបុរេជំនុំជម្រះឈរលើសម្មតិកម្ម ដែលតាមសម្មតិកម្មនេះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ គឺជា"ប្រភេទពិសេសនៃបណ្តឹងឧទ្ធរណ៍" ដែលគេគួរតែអនុវត្តនូវវិធានពិសេសមួយទាក់ទងនឹងសវនាការ ហើយដែលត្រូវសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ទាំងនេះដោយឈរលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីនានា តាមបែបផែនច្បាស់លាស់មួយ។ វិធានបដិបញ្ញត្តិនេះពឹងផ្អែកលើលក្ខណៈសម្ងាត់នៃការស៊ើបសួរ។

6. ប៉ុន្តែ ការពិនិត្យមើលដោយប្រុងប្រយ័ត្ននូវបទបញ្ញត្តិដែលអាចយកមកអនុវត្តបាន ហើយដែលត្រូវបានលើកឡើងដោយអង្គបុរេជំនុំជម្រះដើម្បីគាំទ្រសេចក្តីសម្រេចរបស់ខ្លួន មិនអនុញ្ញាតឱ្យឈានទៅដល់សេចក្តីសន្និដ្ឋានមួយបែបនេះទេ។ ដូច្នេះ នេះគឺជាកំហុសផ្លូវច្បាប់ដ៏ជាក់ស្តែងមួយដែលនឹងត្រូវបានបង្ហាញជូនដូចខាងក្រោមនេះ។

7. ព្រោះថា ជាគោលការណ៍ វិធានទូទៅកំណត់ថា រាល់បណ្តឹងឧទ្ធរណ៍អាចត្រូវបានធ្វើការជជែកពិភាក្សាដោយផ្ទាល់មាត់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ហើយមិនមានប្រភេទពិសេសនៃបណ្តឹងឧទ្ធរណ៍ដែលស្ថិតនៅក្រៅគោលការណ៍នេះទេ។ តាមការពិត លក្ខណៈសម្ងាត់នៃការស៊ើបសួរ

ដែលស្ថិតនៅឆ្ងាយពីការដាក់កម្ហិតដំណើរការដែលអនុម័តដោយអង្គបុរេជំនុំជម្រះ គឺមិនទាក់ទង នឹងអង្គបុរេជំនុំជម្រះទេ ហើយក៏មិនយល់ព្រមជាមួយអង្គបុរេជំនុំជម្រះដែរ។

8. ដូច្នេះ សហមេធាវីការពារក្ដីសូមស្នើដោយទទូចទៅអង្គបុរេជំនុំជម្រះ ឱ្យពិនិត្យមើលឡើងវិញនូវ សេចក្ដីសម្រេចរបស់ខ្លួនទាក់ទងនឹងបញ្ហានេះ។

## ក. អត្ថបទច្បាប់សមហេតុសមផល

### ➢ បណ្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ

9. វិធាន ៧៤.៣ នៃវិធានផ្ទៃក្នុងចែងថា "ជនត្រូវចោទអាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការ របស់សហចៅក្រមស៊ើបអង្កេត"។ ដូច្នេះ អត្ថបទលើកឡើងដោយមិនសួរច្បាស់លាស់ថា "ដីកា របស់សហចៅក្រមស៊ើបអង្កេត៖ ក) ដែលទទួលស្គាល់សមត្ថកិច្ចរបស់ អ.វ.ត.ក។ ខ) ដែល បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរដែលបានអនុញ្ញាតដោយវិធាននេះ។ គ) ដែលបដិសេធ សំណើស្នើសុំមកវិញនូវវត្ថុដែលបានរឹបអូស។ ឃ) ដែលបដិសេធសំណើសុំធ្វើកោសល្យវិច័យ ដែលបានអនុញ្ញាតដោយវិធាននេះ។ ង) ដែលបដិសេធសំណើសុំធ្វើកោសល្យវិច័យជំនាញបន្ថែម ឬ សំណើសុំធ្វើបដិកោសល្យវិច័យដែលអនុញ្ញាតដោយវិធាននេះ។ ច) ដែលទាក់ទងនឹងការឃុំខ្លួន បណ្ដោះអាសន្ន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ។ ឆ) ដែលបដិសេធសំណើសុំប្ដឹងទៅរបស់ អង្គបុរជំនុំជម្រះដើម្បីស្នើសុំមោឃៈភាព។ ជ) ដែលទាក់ទងនឹងវិធានការការពារ។

10. វិធាន ៧៧ នៃវិធានផ្ទៃក្នុង កំណត់នីតិវិធីបណ្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ[4]។

### ➢ គោលការណ៍នៃការពិភាក្សាដេញដោលដោយផ្ទាល់មាត់នៅក្នុងបណ្ដឹងឧទ្ធរណ៍

11. តាមវិធាន ៧៧(៣) ក) នៅពេលដែលអង្គជំនុំជម្រះបានទទួលបណ្ដឹងឧទ្ធរណ៍ "ប្រធានអង្គបុរេ ជំនុំជម្រះ (...) កំណត់កាលបរិច្ឆេទសវនាការ និងជូនដំណឹងទៅក្រឡាបញ្ជីរបស់អង្គបុរេជំនុំ ជម្រះដែលត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ភាគី និងមេធាវីរបស់ពួកគេ"។

12. បន្ទាប់ពីការកែប្រែដែលបានអនុម័តដោយសម័យប្រជុំពេញអង្គ កាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ ២០០៨ និងតាមរយៈអញ្ញត្រកម្មទៅនឹងគោលការណ៍ ចាប់ពីពេលនេះទៅ អង្គបុរេជំនុំជម្រះអាច

---

[4] សូមអានមាត្រា ២៥៨ ថ្មីនៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

"បន្ទាប់ពីបានពិគ្រោះជាមួយភាគី សម្រេចលើបណ្តឹងឧទ្ធរណ៍ (...) ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ"។ (វិធាន ៧៧ (៣) ខ)។

➢ **គោលការណ៍នៃភាពសម្ងាត់នៃកិច្ចពិភាក្សាដេញដោលនៅក្នុងបណ្តឹងឧទ្ធរណ៍**

13. តាមមាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និង វិធាន ៥៦ នៃវិធានផ្ទៃក្នុង "ការស៊ើបសួរត្រូវតែជាការសម្ងាត់"។ ដូច្នេះ វិធាន ៧៧(៥) នៃវិធានផ្ទៃក្នុងចែងថា "សវនាការ[បណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ]ត្រូវធ្វើឡើងជាអសាធារណៈ"។

14. ដោយអនុលោមតាមវិធាន ៧៧(៦) "តាមសំណើរបស់ចៅក្រមណាម្នាក់ ឬរបស់ភាគី <u>អង្គបុរេជំនុំជម្រះអាចសម្រេចថា នីតិវិធីទាំងស្រុង ឬ មួយផ្នែកនៃសវនាការត្រូវធ្វើឡើងជាសាធារណៈ</u> ជាពិសេសនៅពេលដែលសំណុំរឿងនោះអាចត្រូវបានបញ្ចប់ ដោយសេចក្តីសម្រេចរបស់ខ្លួន ដូចជាពាក្យបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំពាក់ព័ន្ធទៅនឹងបញ្ញាយុត្តាធិការ ឬ មូលហេតុដែលនាំឱ្យរលត់បណ្តឹងអាជ្ញា បើអង្គជំនុំជម្រះយល់ឃើញថាដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬវិធានការការពាររបស់តុលាការ។" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)

15. អញ្ញត្រកម្មទៅនឹងគោលការណ៍នេះគឺមានលក្ខណៈសមស្របជាមួយមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (PIDCP) ដែលឧទ្ទិសសិទ្ធិសម្រាប់ "ជនគ្រប់រូប (...) ត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ជំនុំជំរះរឿងក្តីរបស់ខ្លួន ដោយសមធម៌និងជាសាធារណៈ។"

**ខ. អំណះអំណាង**

**១) វិធានទូទៅចែងថា រាល់បណ្តឹងឧទ្ធរណ៍គួរតែធ្វើការពិភាក្សាដេញដោលដោយផ្ទាល់មាត់ នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

- *ជាគោលការណ៍ បណ្តឹងឧទ្ធរណ៍ត្រូវធ្វើការពិភាក្សាដេញដោលដោយផ្ទាល់មាត់នៅចំពោះមុខអង្គបុរេជំនុំជម្រះ*

16. នៅក្នុងរយៈពេលនៃការស៊ើបសួរ នីតិវិធីទាក់ទងនឹងសវនាការបណ្តឹងឧទ្ធរណ៍ត្រូវបានចែងយ៉ាងច្បាស់ដោយមាត្រា ២៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ (CPP) និង វិធាន ៧៧(៣) នៃវិធានផ្ទៃក្នុង

៖ នៅពេលដែលអង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ កាលបរិច្ឆេទសវនាការមួយត្រូវកំណត់។

17. នៅពេលដំបូង គោលការណ៍មិនទទួលយកនូវអញ្ញត្រកម្មណាមួយទេ។ បន្ទាប់ពីការកែប្រែដែលបានអនុម័តដោយសម័យប្រជុំពេញអង្គ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ និងដោយអនុលោមតាមការអនុវត្តរបស់អង្គបុរេជំនុំជម្រះ ចាប់ពីពេលនេះតទៅ វិធាន ៧៧(៣) ចែងអំពីដំណោះស្រាយមួយផ្សេងពីគោលការណ៍។ យោងតាមបទបញ្ញត្តិថ្មីទាំងនេះ ចាប់ពីពេលនេះតទៅ អង្គបុរេជំនុំជម្រះអាច "សម្រេចលើបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ"។ ក៏ប៉ុន្តែយ៉ាងហោចណាស់ ដំណោះស្រាយជំនួសនេះត្រូវបូកផ្សំជាមួយលក្ខខណ្ឌមួយ៖ អង្គបុរេជំនុំជម្រះនឹងត្រូវប្រមែប្រមូលយោបល់របស់ភាគីនានា ដើម្បីសម្រេចថា ត្រូវផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែមួយគត់ប៉ុណ្ណោះ។ នៅក្នុងការអនុវត្ត អង្គបុរេជំនុំជម្រះបានស្វែងរកកិច្ចព្រមព្រៀងមួយ។

18. បទបញ្ញត្តិទាំងនេះអនុលោមទៅនឹងវិធានទូទៅដែលមានចែងនៅមាត្រា ២១ ក) នៃវិធានផ្ទៃក្នុងដែល ដោយយល់ស្របជាមួយច្បាប់អន្តរជាតិ ចែងថា "ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានសមធម៌ និង ត្រូវគោរពគោលការណ៍ចំពោះមុខ"។

- *មិនមាន "ប្រភេទបណ្តឹងឧទ្ធរណ៍ពិសេស" ដែលទាមទារឲ្យមានជាចាំបាច់នូវបដិបញ្ញត្តិ ចំពោះគោលការណ៍នៃកិច្ចពិភាក្សាដេញដោលដោយផ្ទាល់មាត់ទេ។*

19. ករណីផ្សេងៗនៃការបើកបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ត្រូវបានចែងនៅវិធាន ៧៤ នៃវិធានផ្ទៃក្នុង។ តាមអត្ថបទច្បាប់នេះ ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្តីពីការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ។ ករណីបើកបណ្តឹងឧទ្ធរណ៍នេះត្រូវបានពិនិត្យដូចជាបណ្តឹងឧទ្ធរណ៍ដទៃទៀតដែរ ហើយទោះជាយ៉ាងណាក៏ដោយ មិនបង្កើតបានជាប្រភេទពិសេសមួយនោះទេ។

20. ទាក់ទងនឹងបញ្ហានេះ មិនមានអត្ថបទច្បាប់សមហេតុសមផលណាមួយផ្សេងទៀតឡើយ។ លើសពីនេះទៅទៀត អង្គបុរេជំនុំជម្រះមិនបានផ្តល់នូវលក្ខណៈវិនិច្ឆ័យណាមួយដែលអាចបញ្ជាក់ថា ការបង្កើតប្រភេទនេះទេមានលក្ខណៈត្រឹមត្រូវនោះទេ។ ហើយអង្គបុរេជំនុំជម្រះ

00366536



ថែមទាំងមិនបានផ្តល់ឲ្យនូវមូលដ្ឋានដែលខ្លួនសម្អាងលើ ដើម្បីញែកឲ្យដាច់ពីគ្នានូវបណ្តឹងឧទ្ធរណ៍ប្រភេទនេះ ពីករណីផ្សេងៗទៀតដែលមានចែងនៅក្នុងវិធាន ៧៤ ទេ។ ហើយអង្គបុរេជំនុំជម្រះក៏មិនបានពន្យល់ថាហេតុអ្វីបានជាប្រភេទដែលបានអះអាងនេះទាមទារឲ្យមានជាចាំបាច់នូវការពិនិត្យពិសេសមួយ។

21. ផ្ទុយពីអ្វីដែលអង្គបុរេជំនុំជម្រះយល់ស្រប បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្តីពីការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ មិនបង្កើតបានជាប្រភេទបណ្តឹងឧទ្ធរណ៍ពិសេសនោះទេ។ ដូច្នេះនេះជាវិធានទូទៅនៃការពិភាក្សាដេញដោលដោយផ្ទាល់មាត់ដែលចែងដោយអត្ថបទច្បាប់ ដែលត្រូវតែយកមកអនុវត្ត។

**២) លក្ខណៈសម្ងាត់នៃកិច្ចស៊ើបសួរមិនមែនជាមូលហេតុធ្វើឲ្យខូចខាតដល់គោលការណ៍នៃការតទល់គ្នាដោយផ្ទាល់មាត់ពីសំណាក់អង្គបុរេជំនុំជម្រះបានទេ**

- *លក្ខណៈសម្ងាត់នៃកិច្ចស៊ើបអង្កេតមិនមានទំនាក់ទំនងអ្វីជាមួយនឹងគោលការណ៍នៃការតទល់គ្នាដោយផ្ទាល់មាត់ឡើយ។*

22. អង្គបុរេជំនុំជម្រះយល់ឃើញថា គឺជាលក្ខណៈសម្ងាត់នៃកិច្ចស៊ើបសួរដូចដែលមានចែងក្នុងវិធាន ៥៦ នៃវិធានផ្ទៃក្នុង ដែលនាំឲ្យធ្វើដូច្នេះ។ ប៉ុន្តែ វាជាសញ្ញាណពីរដាច់ដោយឡែកពីគ្នាដែលត្រូវបានយល់ច្រឡំនៅទីនេះ៖ ម្យ៉ាង ជាគោលការណ៍ផ្ទាល់មាត់ ម្យ៉ាងទៀត ជាគោលការណ៍រក្សាការសម្ងាត់។ តាមពិត លក្ខណៈសម្ងាត់នៃកិច្ចស៊ើបសួរមិនមានទំនាក់ទំនងអ្វីជាមួយនឹងគោលការណ៍នៃការតទល់គ្នាដោយផ្ទាល់មាត់ឡើយ។ ភាពចាំបាច់នៃការពិភាក្សាដេញដោលតទល់គ្នាលើបញ្ហាមួយនៅចំពោះមុខអង្គចៅក្រម មិនមានទំនាក់ទំនងអ្វីជាមួយនឹងព័ត៌មានដែលលើកយកមកពិភាក្សានេះត្រូវបន្តរក្សាការសម្ងាត់រហូតនោះឡើយ។ នេះជាមូលហេតុដែលនាំឲ្យអត្ថបទច្បាប់ចែងយ៉ាងច្បាស់លាស់ថា នៅក្នុងដំណាក់កាលស៊ើបសួរទាំងមូល សវនាការប្រព្រឹត្តទៅបាន បើទោះជាមានលក្ខណៈសម្ងាត់នៃនីតិវិធីក៏ដោយ។

23. ដូច្នេះ ការដែល "លទ្ធភាពនៃការបើកកិច្ចស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេត នៅតែអាចអនុវត្ត ប្រសិនបើសំណើសុំបំពេញកិច្ចស៊ើបសួរមិនទាន់ត្រូវបានបដិសេធជាស្ថាពរ"[5] ហើយការ

---

[5] សេចក្តីសម្រេចទាក់ទងនឹងសំណើសុំឲ្យមានសវនាការ ដើម្បីពិនិត្យបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿ អ.ប.ជ ២៤ និង ២៥ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ *ឯកសារតុលាការ D164/4/3* កថាខណ្ឌទី ៥ [សំណើសុំឲ្យពិនិត្យមើលឡើងវិញនូវ "សេចក្តីសម្រេចទាក់ទងនឹងសំណើសុំឲ្យមានសវនាការដើម្បីពិនិត្យបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អ.ប.ជ ២៤ និង ២៥]

ដែល "អង្គបុរេជំនុំជម្រះអាច (...) សម្រេចទុកជាមោឃៈដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត និងបញ្ជូនទៅឱ្យពិនិត្យសារជាថ្មីឡើងវិញ ឬចេញដីកាសម្រេចមួយបង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរដែលបានស្នើសុំនោះ" មិនមានការប៉ះពាល់ដោយផ្ទាល់ណាមួយលើការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរឡើយ។ ផ្ទុយមកវិញ កំណត់សម្គាល់នេះតម្រូវឱ្យមានការពិភាក្សាតទល់គ្នា លើកលែងតែមានករណីពិសេស និងដោយបានពិចារណាលើយោបល់របស់ភាគីពាក់ព័ន្ធរួចរាល់ហើយ។ ផ្ទុយមកវិញ "កិច្ចដែលចូលក្នុងកិច្ចស៊ើបសួរនេះដែលមានលក្ខណៈសម្ងាត់ជាទូទៅ" មិនមានផលប៉ះពាល់អ្វីលើចំណុចដែលថា ព័ត៌មានទាំងនេះត្រូវលើកយកមកពិភាក្សាតទល់គ្នាឡើយ។

24. វិធីនេះគឺសមស្របទៅនឹងវិធាន ៧៧(៥) នៃវិធានផ្ទៃក្នុងដែលចែងថា ជាគោលការណ៍ "សវនាការត្រូវធ្វើឡើងជាអសាធារណៈ"។ ជាការពិត ទៅតាមសំណើរបស់ចៅក្រមម្នាក់ ឬរបស់ភាគីមួយ អង្គបុរេជំនុំជម្រះអាចសម្រេចដោយខ្លួនឯងថា នីតិវិធីទាំងស្រុង ឬ មួយផ្នែកនៃសវនាការត្រូវធ្វើឡើងជាសាធារណៈ តែនៅក្នុងលក្ខខណ្ឌដែលខ្លួនយល់ឃើញថា ដើម្បីជាប្រយោជន៍ដល់យុត្តិធម៌ និងមិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ វិធានការការពាររបស់តុលាការប៉ុណ្ណោះ។ ដូច្នេះ ច្បាប់ដែលអាចអនុវត្តបានផ្តល់នូវការធានាគ្រប់យ៉ាង ដើម្បីអាចឱ្យធានាបាននូវភាពសម្ងាត់នៃការស៊ើបសួរ និងឆ្លើយតបទៅនឹងក្តីកង្វល់ដែលលើកឡើងដោយអង្គបុរេជំនុំជម្រះ។

- *បដិបញ្ញត្តិដែលបានបង្កើតឡើងមិនមានមូលដ្ឋានច្បាប់ទេ ហើយដាក់កម្រិតដល់សិទ្ធិរបស់ជនត្រូវចោទ*

25. អង្គបុរេជំនុំជម្រះយល់ឃើញថា ការវិនិច្ឆ័យទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសំណើសុំឱ្យមានកិច្ចស៊ើបសួរត្រូវតែឈរទៅលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគី ជាស្វ័យប្រវត្តិព្រោះថាសំណើទាំងនេះត្រូវតែស្ថិតក្នុងលក្ខណៈសម្ងាត់ និងការស៊ើបសួរសម្ងាត់។

26. សេចក្តីសន្និដ្ឋាននេះឈរលើកំហុសឆ្គងផ្លូវច្បាប់ចំនួនពីរ៖ ផ្ទុយទៅនឹងអ្វីដែលបានលើកឡើងពីពេលមុន ១) វិធានទូទៅសម្រាប់រាល់បណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះត្រូវតែធ្វើឡើងតាមរយៈសវនាការមួយ។ ការវិនិច្ឆ័យដោយឈរទៅលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីអាចធ្វើទៅបាន ក៏ប៉ុន្តែនេះគ្រាន់តែជាករណីអញ្ញតិកម្មមួយទៅនឹងគោលការណ៍

ប៉ុណ្ណោះ។ ២) វិធានសម្រាប់រាល់បណ្ដឹងឧទ្ធរណ៍គឺតម្រូវឱ្យសវនាការធ្វើឡើងជាអសាធារណៈ ចំណែកឯសវនាការដែលធ្វើឡើងជាសាធារណៈត្រូវតែគោរពទៅតាមលក្ខខណ្ឌមួយចំនួន។

27. ជាងនេះទៅទៀត ការបកស្រាយរបស់អង្គបុរេជំនុំជម្រះមិនឈរលើអត្ថបទច្បាប់ណាមួយដែលអាចឱ្យទទួលស្គាល់ការលើកហេតុផលបែបនេះថា មានភាពត្រឹមត្រូវតាមច្បាប់ទាល់តែសោះ មិនថាឡើយច្បាប់ក្នុងប្រទេស ឬច្បាប់អន្តរជាតិក្ដី។ ជាចុងបញ្ចប់ ការបកស្រាយនេះឈានទៅដល់ការរឹតត្បិតសិទ្ធិទទួលបានសវនាការលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ដែលនាំឱ្យផ្ទុយទៅនឹងវិធាន ៥៦ ដែលចែងថា ការស៊ើបសួរគឺមានលក្ខណៈសម្ងាត់ «ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍របស់ភាគី»។

## II- សំណើរបស់ក្រុមការពារក្ដី សុំឱ្យពិនិត្យមើលឡើងវិញនូវសំណើសុំឱ្យមានការរៀបចំសវនាការ

28. នៅក្នុងបណ្ដឹងឧទ្ធរណ៍ អ្នកប្ដឹងឧទ្ធរណ៍ទាំងបីបានស្នើសុំយ៉ាងជាក់លាក់ដល់អង្គបុរេជំនុំជម្រះឱ្យស្ដាប់សេចក្ដីសម្អាងផ្ទាល់មាត់របស់ពួកគេ។ ជាពិសេស ពួកគេបានលើកឡើងថា "ដែនអនុវត្តន៍ការស៊ើបសួរគឺជាបញ្ហាចម្បងមួយក្នុងនីតិវិធីនៅចំពោះមុខអវតក [ហើយថា] ដូច្នេះ បញ្ហានេះមានសារៈសំខាន់ខ្ពស់បំផុតដែលតម្រូវឱ្យមានការពិភាក្សាយ៉ាងពេញលេញ និងត្រូវបានដោះស្រាយនៅចំពោះមុខអង្គបុរេជំនុំជម្រះ"[6]។

29. ផ្ទុយទៅវិញ នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា "បណ្ដឹងឧទ្ធរណ៍ទាំងនេះមិនបានលើកឡើងពីអង្គច្បាប់ដែលមានលក្ខណៈស្មុគស្មាញនោះទេ ប៉ុន្តែបានលើកឡើងពីសញ្ញាណជាក់ស្ដែងនៃនីតិវិធី ហើយដែលបណ្ដឹងឧទ្ធរណ៍ទាំងនេះត្រូវតែទទួលបានការជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃការធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរ ដើម្បីឆ្លើយតបទៅនឹងអត្ថប្រយោជន៍នៃប្រព័ន្ធតុលាការ" [7]។

---

[6] បណ្ដឹងឧទ្ធរណ៍តែមួយគត់របស់មេធាវីការពារក្ដីប្រឆាំងនឹងដីកាសម្រេចចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ របស់សហចៅក្រមស៊ើបអង្កេតស្ដីពីសំណើសុំបំពេញកិច្ចស៊ើបសួរដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងសំណុំឯកសាររួម។ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩។ *ឯកសារតុលាការលេខ D164/4/1 កថាខណ្ឌទី ៨*

[7] ចម្លើយតបរបស់សហព្រះរាជអាជ្ញាដែលមានបញ្ជាក់នៅក្នុងសេចក្ដីសម្រេចទាក់ទងនឹងសំណើសុំឱ្យមានសវនាការ ដើម្បីពិនិត្យបណ្ដឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អ.ប.ជ ២៤ និង ២៥ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ *ឯកសារតុលាការ D164/4/3 កថាខណ្ឌទី ៣*

30. អង្គបុរេជំនុំជម្រះមិនបានពិនិត្យទឡ្ហីករណ៍ទាំងឡាយរបស់ភាគី ទាក់ទងដល់ចំណុចនេះឡើយ។ អង្គបុរេជំនុំជម្រះគ្រាន់តែបានចាត់ទុកថា បណ្តឹងឧទ្ធរណ៍នេះស្ថិតក្នុងប្រភេទនៃបណ្តឹងឧទ្ធរណ៍ដែលមិនចាំបាច់តម្រូវឱ្យមានការបើកសវនាការសម្រេចសេចក្តីទេ។ ដូចដែលអ្វីដែលបានគូសបញ្ជាក់ មិនមានប្រភេទនៃបណ្តឹងឧទ្ធរណ៍នេះទេ។ ដូច្នេះ សហមេធាវីការពារក្តីសូមស្នើឱ្យអង្គបុរេជំនុំជម្រះពិនិត្យលើទឡ្ហីករណ៍ដែលលើកឡើងដោយភាគី និងសម្រេចថា តើខ្លួនយល់ឃើញដូចក្រុមការពារក្តីដែរឬទេថា ដោយយោងលើលក្ខណៈពិសេសនៃបណ្តឹងឧទ្ធរណ៍ សម្រាប់កិច្ចស៊ើបសួរនេះ ការបើកសវនាការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នេះគួរតម្រូវឱ្យមានជាចាំបាច់ ហើយថាតើនៅក្នុងលក្ខខណ្ឌបែបណាខ្លះដែលសវនាការនេះធ្វើឡើងដើម្បីជាប្រយោជន៍ដល់ដំណើរការនៃអង្គជំនុំជម្រះ។

## តាមរយៈហេតុផលទាំងនេះ

31. សហមេធាវីការពារក្តីសូមស្នើដល់អង្គបុរេជំនុំជម្រះមេត្តា៖

- **ពិចារណាឡើងវិញ**អំពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលរឹតត្បិតសិទ្ធិក្នុងការទទួលបាននូវសវនាការលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ
- **ពិនិត្យជាក់ស្តែងលើយោបល់ដែលលើកឡើងដោយភាគី** ស្តីពីការបើកអង្គសវនាការ **និងសម្រេចអំពីថ្ងៃ**បើកសវនាការ។

**គោរពសិទ្ធិកែប្រែគ្រប់បែបយ៉ាង**
**និងដើម្បីយុត្តិធម៌**

| | មេធាវី ស សុវាន<br><br>មេធាវី Jacques **VERGÈS** | ភ្នំពេញ<br><br>ប៉ារីស | 1. [signature]<br><br>P. 1. [signature] |
|---|---|---|---|
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |